ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ
លេខ: ១២៥៥/១៥ ក.អ.ជ

ថ្ងៃព្រហស្បតិ៍ ១ កើត ខែទុតិយាសាឍ ឆ្នាំមមែ សប្តស័ក ព.ស. ២៥៥៩
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា គ.ស ២០១៥

**រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ**
**ជម្រាបមក**
**លោក សេវ លឿត តំណាងសហគមន៍ជនជាតិដើមភាគតិច ចារាយ**
**ភូមិប៉ាតាង ឃុំសេសាន ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី**

**កម្មវត្ថុ:** ស្តីពីការទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិប៉ាតាង ឃុំសេសាន ស្រុកអូរយ៉ាដាវ

**យោង:** - សំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិប៉ាតាង របស់លោក សេវ លឿត តំណាងសហគមន៍ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ។

- លិខិតលេខ ៥០២/១៥ ឈ.អ.ខ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីសំណើសុំទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិប៉ាតាង របស់អភិបាល នៃគណៈអភិបាលខេត្តរតនគិរី។
- លទ្ធផលវាយតម្លៃអត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិប៉ាតាង របស់ក្រុមការងារនាយកដ្ឋានអភិវឌ្ឍន៍ជនជាតិភាគតិច នៃក្រសួងអភិវឌ្ឍន៍ជនបទ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោកជ្រាបថា ក្រសួងអភិវឌ្ឍន៍ជនបទ យល់ព្រមទទួលស្គាល់អត្តសញ្ញាណសហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិប៉ាតាង ឃុំសេសាន ស្រុកអូរយ៉ាដាវ ខេត្តរតនគិរី តាមសំណើ។ សហគមន៍ជនជាតិដើមភាគតិច ចារាយ ភូមិប៉ាតាង អាចប្រើប្រាស់លិខិតទទួលស្គាល់អត្តសញ្ញាណនេះ ក្នុងសកម្មភាពបម្រើដល់ផលប្រយោជន៍រួមរបស់សហគមន៍ ផលប្រយោជន៍សង្គម និងផលប្រយោជន៍ជាតិ តាមការចាំបាច់ស្របតាមគោលនយោបាយ ច្បាប់ បទបញ្ញត្តិ និងលិខិតបទដ្ឋានទាំងឡាយ នៃព្រះរាជាណាចក្រកម្ពុជា។

សូមលោក ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំ។

ចម្លងជូន
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងបរិស្ថាន
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
-ក្រសួងទេសចរណ៍
"ដើម្បីជូនជ្រាប"
-សាលាខេត្តរតនគិរី
-មន្ទីរអភិវឌ្ឍន៍ជនបទខេត្តរតនគិរី
"ដើម្បីអនុវត្ត"
-ឯកសារ - កាលប្បវត្តិ

ជា សុផារ៉ា

អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com